# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី

លេខ : ១៧....សសរ.......

# សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតក្រុមប្រឹក្សាវិន័យ

## ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ១០ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៧ ស្ដីពីនីតិវិធីនៃការអនុវត្តវិន័យចំពោះមន្ត្រីរាជការ
- យោងតាមការចាំបាច់

## សម្រេច

**ប្រការ១.-**

បង្កើតក្រុមប្រឹក្សាវិន័យនៃទីស្ដីការគណៈរដ្ឋមន្ត្រី ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តមបណ្ឌិតសភាចារ្យ | **ហ៊ីុង ថូរ៉ាក់ស៊ី** | រដ្ឋលេខាធិការប្រចាំការ | ជាប្រធាន |
| ២. ឯកឧត្តម | **សំ ម៉ិនណា** | អនុរដ្ឋលេខាធិការ | ជាអនុប្រធាន |
| ៣. លោក | **ពៅ ចាន់ម៉ុផល** | ប្រធានស្ដីទីនាយកដ្ឋានបុគ្គលិក | ជាសមាជិក |

៤. អគ្គនាយក ប្រធាននាយកដ្ឋាន ឬប្រធានអង្គភាពចំណុះទីស្ដីការគណៈរដ្ឋមន្ត្រី ដែលមានមន្ត្រីរាជការមានកំហុស ជាសមាជិក។

**ប្រការ២.-**

ក្រុមប្រឹក្សាវិន័យ មានតួនាទី និងភារកិច្ចដូចតទៅ៖

- សិក្សាស្រាវជ្រាវរាល់សកម្មភាពរបស់មន្ត្រីរាជការក្រោមឱវាទទីស្ដីការគណៈរដ្ឋមន្ត្រី
- ណែនាំអប់រំ និងជំរុញការគោរពវិន័យដល់មន្ត្រីរាជការ
- ត្រួតពិនិត្យរាល់កំហុសឆ្គងរបស់មន្ត្រីរាជការស៊ីវិល
- ពិនិត្យ និងសម្រេចដាក់ទណ្ឌកម្មថ្នាក់លេខ១ និងថ្នាក់លេខ២ ដល់មន្ត្រីរាជការដែលមានកំហុសធ្ងន់ធ្ងរ ស្របតាមច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- ធ្វើរបាយការណ៍អំពីសកម្មភាពដែលពាក់ព័ន្ធនឹងវិន័យការងាររបស់មន្ត្រីរាជការ ជូនថ្នាក់ដឹកនាំទីស្ដីការគណៈរដ្ឋមន្ត្រី។

**ប្រការ៣.-**

អនុប្រធាន និងសមាជិកក្រុមប្រឹក្សាវិន័យខាងលើ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ៤.-**

សេចក្ដីសម្រេចលេខ៣១ សសរ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៨ ស្ដីពីការបង្កើតក្រុមប្រឹក្សាវិន័យ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

**កន្លែងទទួល :**

- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៥
- ឯកសារ-កាលប្បវត្តិ